


រៀបរៀងដោយលោក អ៊ុម បូរិន្ទ

ព្រះពុទ្ធសករាជព្រះសាសនាអតិកន្តា កន្លងទៅហើយបាន ២៥៥១ ត្រឹមថ្ងៃ១៥កើត ខែពិសាខ លុះដល់ថ្ងៃ១រោច ខែពិសាខ ឆ្នាំជូត សំរឹទ្ធិស័កតទៅ ចូលពុទ្ធសករាជ ២៥៥២ ។ នឹងគណនាឆ្នាំជូត ឥឡូវនេះ សង្ក្រាន្តចូលមកនៅថ្ងៃអាទិត្យ ៨កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៣ ខែមេសា គ.ស ២០០៨ វេលាម៉ោង ១៨ និង២៤នាទី ។ ពេលនោះ ព្រះអាទិត្យ ចេញពីមីនរាសីទៅស្ថិតនៅឯមេសរាសីតាមផ្លូវគោវិថី គឺផ្លូវកណ្តាលទើបមានទេពធីតាមួយព្រះអង្គជាមគ្គនាយិកា ព្រះនាម ធុង្សៈទេវីជាបុត្រីទី១ នៃកបិលមហាព្រហ្ម គង់នៅចាតុម្មហារាជិកា ទ្រង់អម្ពរពណ៌ក្រហម លំអនៅព្រះកាណ៌ដោយផ្កាទទឹមអភរណៈទ្រង់ពាក់កែវបទុមរាគភក្សាហារ ទ្រង់សោយផ្លែ ឧទុម្ពរ ព្រះហស្តស្តាំទ្រង់ចក្រ ព្រះហស្តឆ្វេង ទ្រង់ស័ង្ខ ទ្រង់គង់ពាក់ឆៀង បើកព្រះនេត្រលើខ្នងសត្វគ្រុឌបក្សីជាពាហនៈ ទើបនាំអស់ទេវបុត្រ ទេវធីតា ទាំងមួយសែនកោដិហោះទៅកាន់គុហាកែវ ធម្មមាលីនាទីភ្នំកៃលាស ខេត្តហិមពាន្ត ជាទីតំកល់ទុកនូវព្រះសិរសាកបិលមហាព្រហ្ម ដែលតំកល់លើពានមាសនាំមកដង្ហែប្រទក្សិណភ្នំព្រះសុមេរុរាជតាមផ្លូវព្រះអាទិត្យចរចំនួន៦០នាទី (២៤ម៉ោង) ទើបនាំយកទៅតំកល់ទុកកន្លែងដើមវិញ ហើយប្រជុំទេវបុត្រទេវធីតាទាំងមួយសែនកោដិចូលទៅស្រង់ទឹកអនោតត្តមហាស្រះ ដែលមានទឹកហូរចេញពីបំពង់ថ្មកែវដែលជាមាត់គោឧសភរាជទាំង ៧ត្រជាក់ក្សេមក្សាន្តព្រះរាជហឫទ័យ ហើយនាំគ្នាចូលទៅសមាទាន

រក្សាសីលដោយសោមនស្សរីករាយគ្រប់ព្រះអង្គក្នុងភគវតីសភាសាលា ដែលវិស្សកម្មទេវបុត្រនិមិត្តថ្វាយ ដើម្បីបន្ទោបង់អពមង្គលឱ្យជ្រះស្រឡះ ហើយចំរើននូវសិរីសួស្តី ជ័យមង្គល ជន្មាយុឃឹនយូរដល់ទេវតា និងមនុស្សសត្វផងទាំងឡាយតាំងពីឆ្នាំថ្មីចូលមកនេះបានធូរទូលំទូលាយសុខក្សេមក្សាន្តតរៀងទៅ។

ថ្ងៃអាទិត្យ ៨កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៣ ខែមេសា គ្រឹស្តសករាជ២០០៨ វេលាម៉ោង ១៨ និង ២៤ នាទី ជាថ្ងៃចូលឆ្នាំជូត សំរឹទ្ធិស័ក ។

ថ្ងៃច័ន្ទ ៩កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ្រឹស្តសករាជ ២០០៨ ជាវារៈវ័នបត។

ថ្ងៃអង្គារ៍ ១០កើត ខែចេត្រ ត្រូវនឹងថ្ងៃទី១៥ ខែមេសា គ្រឹស្តសករាជ២០០៨ នៅវេលាម៉ោង២២ និង ២៣នាទី ៥៨វិនាទី ជាវារៈឡើងស័ក គំរប់ជាសង្រ្កាន្តបីថ្ងៃស្រេចបរិបូរណ៌ចូលជាសាកលឆ្នាំជូត សំរិទ្ធិស័ក ចុល្លសករាជ ១៣៧០តទៅ ។

ក្នុងឱកាសសង្រ្កាន្តទាំងបីថ្ងៃ សូមអស់ប្រជាពលរដ្ឋប្រុសស្រីផងទាំងឡាយរៀបចំពលិការគ្រឿងសក្ការៈបូជាអុជប្រទីបផ្កាលាថ្វាយព្រះរតនត្រ័យ និងទទួលស្វាគមន៏ទេវបុត្រទេវធីតាឆ្នាំថ្មី ហើយខំលះបង់ចិត្តអាក្រក់អន្សត្តិរិយជាចិត្តអប្រិយជាប់ដោយគំនុំគុំគួនព្យាបាទឈ្នានីស ដែលកើតមានក្នុងឆ្នាំចាស់ឱ្យជ្រះស្រឡះតាំងចិត្តប្រព្រឹត្តល្អប្រកបដោយមេត្តា ករុណា មុទិតា ឧបេក្ខា និងបញ្ញាធ្វើបុណ្យសុន្ទរ៍ទានតាមប្រពៃណី រក្សាសីលប្រាំឱ្យបានជាប់ជានិច្ចនោះ ទើបទេវតានឹងឱ្យពរសព្វសាធុការ លោកអ្នកនឹងមានសិរីសួស្តីសុភមង្គល វិបុលសុខគ្រប់ប្រការតាំងពីឆ្នាំថ្មីនេះតរៀងទៅ ។

## របៀបទទួលទេវតា

របៀបទទួលទេវតាតាមទំនៀមទំលាប់រៀងរហូតមក មានរានទទួលទេវតាមួយ សំរាប់តាំងគ្រឿងពលិការផ្សេងៗ។ ត្រូវរៀបក្រាលសំពត់ពណ៌ស ហើយរៀបបាយសី ៩ថ្នាក់មួយគូ បាយសី ៧ថ្នាក់មួយគូ បាយសី ៥ថ្នាក់មួយគូ បាយសី ៣ថ្នាក់មួយគូ បាយសីប៉ាឆាមមួយគូ ស្លាធម៌មួយគូ ទឹកអប់មួយគូ ទៀន៥ ធូប៥ លាជ៥ ផ្កាដាក់លើជើងពាន ១គូ ចេកនួន ចេកណាំវ៉ាមួយគូ ផ្លែឈើ ១១មុខរៀបដាក់ជើងពានជាគូៗ ដូងឡៅមួយគូ ។ នៅក្នុងឆ្នាំថ្មីនេះគួរដាក់ផ្លែល្វាសំរាប់ទេវតាផង ។

ចំពោះបាយសី ៩ថ្នាក់ ៧ថ្នាក់ សំរាប់នៅព្រះបរមរាជវាំង ចំពោះប្រជារាស្រ្តគួរធ្វើត្រឹម ៥ថ្នាក់ចុះមក

ក៏ល្អដែរ ។ ចំណែកផ្លែឈើវិញ សំរាប់ប្រជារាស្ត្រគួររៀបឱ្យបានត្រឹម ៣ ឬ៥មុខជាការប្រសើរ តែបើសម្បូរណ៍បានដល់ ១១មុខ ក៏រឹតតែប្រសើរ ។

ផ្សព្វផ្សាយទូលំទូលាយសម្រាប់ធម្មទានដោយទូរទស្សន៍ Templenews
www.templenews.info

ប្រភពពត៌មាន : សារពត៌មានកោះសន្តិភាព ថ្ងៃអង្គារ៍ ទី០៨ ខែមេសា ព.ស.២៥៥១/គ.ស.២០០៨
Source: Koh Santepheap Newspaper Wednesday April 8, B.E.2551/C.E.2008